# សេចក្តីប្រកាសព័ត៌មាន

## អង្គការ WWF-កម្ពុជា និងដៃគូនានា ដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទេសចរណ៍បៃតង ដើម្បីការពារតំបន់ទេសភាពព្រៃលិចទឹកមេគង្គ និងបង្កើនជីវភាពរស់នៅរបស់សហគមន៍

**ខេត្តក្រចេះ ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២៦៖** អង្គការ WWF-កម្ពុជា ក្នុងភាពជាដៃគូជាមួយមន្ទីរទេសចរណ៍ខេត្ត និងអង្គការដៃគូនានា នៅថ្ងៃនេះ បានដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងទេសចរណ៍បៃតងនៅតំបន់ទេសភាពព្រៃលិចទឹកមេគង្គ ដើម្បីការពារធនធានធម្មជាតិ និងបង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយស្ថិតនៅខេត្តក្រចេះ។ គម្រោងនេះនឹងជួយលើកកម្ពស់ទេសចរណ៍បៃតងនៅតំបន់ទេសភាពព្រៃលិចទឹកមេគង្គ (MFF) ដោយភ្ជាប់ការអភិរក្សប្រព័ន្ធអេកូឡូស៊ីសំខាន់ៗជាមួយនឹងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់សហគមន៍ក្នុងតំបន់។

គាំទ្រជំនួយមូលនិធិពីអង្គការអន្តរជាតិ International Organization of La Francophonie (OIF) និងជាផ្នែកមួយនៃម្រោងសក្តានុពលគោលដៅអេកូទេសចរណ៍ (Destination Eco-Talents) គម្រោងនេះត្រូវបានរៀនចំឡើយដោយផ្អែកលើបទពិសោធន៍របស់អង្គការ WWF-កម្ពុជា ក្នុងការអភិរក្សផ្អែកលើសហគមន៍ និងទេសចរណ៍ប្រកបដោយចីរភាព។ គម្រោងរយៈពេល ១៤ ខែនេះ មានគោលបំណងអភិវឌ្ឍផលិតផលអេកូទេសចរណ៍ដែលមានផលប៉ះពាល់ទាប ដែលបង្ហាញពីប្រព័ន្ធអេកូឡូស៊ីទន្លេ និងបេតិកភណ្ឌវប្បធម៌របស់ខេត្តក្រចេះ ព្រមទាំងបង្កើតឱកាសប្រកបរបរចិញ្ចឹមជីវិតដោយចីរភាពជាពិសេសសម្រាប់ស្ត្រី និងយុវជន។

លោកបណ្ឌិត Dipankar Chyau Patnaik នាយកអង្គការ WWF-កម្ពុជា មានប្រសាសន៍ថា៖ «គម្រោងនេះបង្ហាញថា ការអភិរក្ស និងជីវភាពរស់នៅរបស់សហគមន៍ គឺត្រូវតែដើរទន្ទឹមគ្នាដោយមិនអាចអត់ម្ខាងណាបានឡើយ ដោយសង្កត់ធ្ងន់ថា ការពង្រឹងវិស័យអេកូទេសចរណ៍ដែលមានមូលដ្ឋាននៅសហគមន៍ និងការភ្ជាប់ទៅនឹងទីផ្សារប្រកបមុខរបរ គឺយើងកំពុងផ្តល់នូវអត្ថប្រយោជន៍គ្រប់ជ្រុងជ្រោយជាពិសេសនោះដើម្បីការពារតំបន់ទេសភាពព្រៃលិចទឹកមេគង្គ។ តំបន់ទេសភាពនេះ គឺជាប្រព័ន្ធអេកូឡូស៊ី

ដ៏សំខាន់បំផុតមួយរបស់ប្រទេសកម្ពុជា ដែលជាជម្រករបស់សត្វផ្សោតដែលជារតនសម្បត្តិជាតិមានជីវិតរបស់កម្ពុជា និងសម្បូរទៅដោយជីវៈចម្រុះគ្រប់ប្រភេទ ហើយគោលដៅរបស់យើង គឺជានាថាសហគមន៍ក្នុងតំបន់ ជាពិសេសស្ត្រី និងយុវជននឹងទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីកិច្ចខិតខំប្រឹងប្រែងអភិរក្សទាំងនេះ»។

សកម្មភាពរបស់គម្រោងនឹងត្រូវបានអនុវត្តនៅសហគមន៍អេកូទេសចរណ៍កោះព្រះព្រហ្មចារីយ៍ និងកោះផ្ដៅ ដែលជាសហគមន៍កោះទន្លេពីរ ដែលមានទីតាំងនៅជិតទីជម្រករបស់សត្វផ្សោតទន្លេមេគង្គ។ សហគមន៍អេកូទេសចរណ៍(CBET) នៅក្នុងតំបន់ទាំងនេះ នឹងទទួលបានការគាំទ្រលើផលិតផលទេសចរណ៍ ការកែលម្អគុណភាពសេវាកម្ម និងការភ្ជាប់ទំនាក់ទំនងកាន់តែមានប្រសិទ្ធភាពជាមួយប្រតិបត្តិករទេសចរណ៍ និងទីផ្សារទេសចរណ៍ឱ្យកាន់តែទូលំទូលាយទាំងក្នុងស្រុក និងក្រៅស្រុក។

ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ បានគូសបញ្ជាក់ពីភាពស៊ីសង្វាក់គ្នានៃគម្រោងនេះជាមួយនឹងអាទិភាពអភិវឌ្ឍន៍ខេត្តថា៖ «តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការរវាងសហគមន៍ វិស័យឯកជន និងស្ថាប័នរដ្ឋាភិបាល គម្រោងនេះ គឺទទួលបានការគាំទ្រពីខេត្តក្រចេះ ដែលនឹងរួមចំណែកធ្វើឱ្យវិស័យសហគមន៍អេកូទេសចរណ៍នៅក្នុងខេត្តមួយនេះកាន់តែរីកចម្រើន ហើយចូលរួមយ៉ាងសកម្មក្នុងកាការពារធនធានធម្មជាតិ»។

សូមបញ្ជាក់ថា លទ្ធផលសំខាន់ៗដែលរំពឹងទុកនៃគម្រោងនេះ រួមមាន ផលិតផលទេសចរណ៍ដែលមានទំនួលខុសត្រូវចំពោះបរិស្ថានកាន់តែច្រើននៅក្នុងខេត្តក្រចេះ និងតំបន់ទេសភាពព្រៃលិចទឹកមេគង្គ ការយល់ដឹងកាន់តែច្បាស់របស់សហគមន៍អំពីការអភិរក្សជីវៈចម្រុះ ឱកាសរកប្រាក់ចំណូលកាន់តែប្រសើរឡើងសម្រាប់សមាជិកសហគមន៍អេកូទេសចរណ៍(CBET) និងទំនាក់ទំនងកាន់តែរឹងមាំរវាងភ្នាក់ងារអេកូទេសចរណ៍មូលដ្ឋាន និងនៅកម្រិតថ្នាក់ជាតិ។

លោកស្រី Adjara Diouf អ្នកសម្របសម្រួលគម្រោង Destination Eco-Talents មានប្រសាសន៍ថា៖ «ការលើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាព តាមរយៈជំនួយមូលនិធិពី OIF នាពេលនេះបានឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរួមគ្នាចំពោះកំណើនទេសចរណ៍បៃតង។ យើងមានសេចក្ដីសោមនស្សរីករាយក្នុង

ការគាំទ្រប្រទេសកម្ពុជាក្នុងការលើកកម្ពស់គំរូទេសចរណ៍ដែលឱ្យតម្លៃដល់ធម្មជាតិ វប្បធម៌ និងប្រជាជន ហើយអាចកៀរគរឱ្យមានការចូលរួមរបស់ស្ត្រី និងយុវជនកាន់តែច្រើន»។

តាមរយៈសិក្ខាសាលានាថ្ងៃនេះ ដែលកំពុងរៀបចំនៅសណ្ឋាគារហោប៊ុននី ក្នុងខេត្តក្រចេះ មានការចូលរួមពីតំណាងមកពីមន្ទីរពាក់ព័ន្ធខេត្ត អាជ្ញាធរមូលដ្ឋាន សហគមន៍អេកូទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ វិស័យឯកជន និងអង្គការដៃគូនានា ដើម្បីចែករំលែកព័ត៌មានអំពីគម្រោង និងពង្រឹងកិច្ចសហការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**###**

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លោក ឆេង សំបូរ ប្រធានផ្នែកកិច្ចការសាធារណៈ ចំណេះ និងព័ត៌មាន តាមរយៈ៖** pressdesk@wwf.org.kh.